# អ្នកនាំសារ
The Messenger

49

ថ្ងៃទី ០១-១៥ ខែកក្កដា  ឆ្នាំ២០០៧- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ





## លោកប៉ុងសូជ៍ៈ "ដើម្បីឱ្យយុវជនស្គាល់ប្រវត្តិខ្មែរ"



កុមារនៅតែ
មានថ្ងៃសិទ្ធិ

ទំព័រ ៩



របាំឆៃយាំ ជារបាំ
ប្រពៃណីដ៏យូរ
លង់

ទំព័រ ១០

តើដាំចេកអំបូង
តាមបច្ចេកទេស
យ៉ាងម៉េច?

ទំព័រ ១១

## ចំណេះដឹង

### ជីវប្រវត្តិនៃព្រះករុណា ព្រះបរមនាថ ព្រះបាទនរោត្តម សីហមុនី



Photo: DR

ពីឆ្នាំ១៩៥៩-១៩៦២ : សិក្សាសាលាបឋមសិក្សានរោត្តម-វិទ្យាល័យដេកាត (ភ្នំពេញ) ព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំ១៩៦២-១៩៦៧ : សាលាបឋមសិក្សា និងមធ្យមសិក្សានៅវិទ្យាល័យប្រាគ្រ (នៅប្រទេសឆេកូស្លូវ៉ាគី)។

១៩៦៧-១៩៧១ : សិក្សាផ្នែកសិល្បៈ (របាំ-តូរ្យតន្ត្រី-ល្ខោន) នៅវិទ្យាស្ថានអភិរក្សជាតិនៅប្រាគ្រ។

១៩៧០ : ទទួលមធ្យមសិក្សាប័ត្រនៅប្រាគ្រ (និទ្ទេសល្អណាស់)។

១៩៧១ : រង្វាន់លេខ១ ផ្នែករបាំបុរាណនៅវិទ្យាស្ថានអភិរក្សជាតិនៅប្រាគ្រ។

១៩៧១-១៩៧៥ : ឧត្តមសិក្សាផ្នែករបាំ-តូរ្យតន្ត្រី និងល្ខោននៅបណ្ឌិត្យសភានៃផ្នែកវិជ្ជាតូរ្យតន្ត្រីនៅប្រាគ្រ។

១៩៧៥ : សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកសិល្បៈរបាំតូរ្យតន្ត្រីល្ខោននៃបណ្ឌិតសភាផ្នែកវិជ្ជាតូរ្យតន្ត្រីនៅប្រាគ្រ។

១៩៧៥ : និពន្ធនិក្ខេបបទស្ដីពីទស្សនៈ និងការគ្រប់គ្រងសាលាសិល្បៈនៅកម្ពុជា។

១៩៧៥-១៩៧៦ : ឧត្តមសិក្សាខាងផ្នែកភាពយន្តនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។

១៩៧៦-១៩៧៩ : ជាប់ឃុំខ្នាំក្រហមជាមួយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សម្ដេចព្រះរាជអគ្គមហេសី និងព្រះអនុជព្រះអង្គម្ចាស់នរោត្តមនរិន្ទ្រៈពង្ស។

១៩៧៩-១៩៨០ : ព្រះលេខាផ្ទាល់ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្ដេចព្រះរាជអគ្គមហេសី ក្នុងពេលព្រះអង្គ ទ្រង់គង់ប្រថាប់នៅបរទេស។

តទៅលេខក្រោយ

## អធិប្បាយព្រះបន្ទូល

### ថ្ងៃអាទិត្យទី១២ ក្នុងរដូវធម្មតា (ថ្ងៃទី២៤ មិថុនា ឆ្នាំ២០០៧)

"តើអ្នកប្រាប់ថា ខ្ញុំជានរណាដែរ?" (លូកា ១,៥៧-៦៦. ៨០)

នាថ្ងៃនេះព្រះយេស៊ូសួរយើងម្នាក់ៗថា: "តើអ្នកប្រាប់ថា ខ្ញុំជានរណាដែរ?"។ តើបងប្អូនឆ្លើយតបយ៉ាងណាដែរ? តើបងប្អូនថា ព្រះយេស៊ូជានរណា? បងប្អូនមានទំនាក់ទំនងជាមួយព្រះអង្គយ៉ាងណា? នៅពេលបងប្អូនពុទ្ធបរិស័ទសួរបងប្អូនអំពីព្រះយេស៊ូដែលខ្លួនគោរពថ្វាយបង្គំ តើបងប្អូនឆ្លើយយ៉ាងណា? យើងអាចឆ្លើយតបតាមទ្រឹស្ដីដែលយើងបានរៀន គឺថាព្រះយេស៊ូជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះ ឬជាព្រះអម្ចាស់-ល-។ តើព្រះនាមទាំងនោះមានអត្ថន័យយ៉ាងណា? ចំពោះបងប្អូនម្នាក់ៗ ឬព្រះនាមទាំងនេះគ្រាន់តែពាក្យប៉ុណ្ណោះឬ? ឬព្រះនាមដែលបងប្អូនហៅនេះ គឺបង្ហាញអំពីទំនាក់ទំនងរបស់បងប្អូនជាមួយព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅយ៉ាងណា?

លោកសិលាតបឆ្លើយទៅនឹងសំណួរនេះថា: "លោកជាព្រះគ្រីស្ដ" គឺគាត់រាប់លោកគ្រូយេស៊ូ ទុកជាអ្នកដែលអាចផ្ដល់សេចក្ដីសុខសាន្តដ៏ពិតប្រាកដឱ្យមនុស្សលោក ឬជាអ្នកធ្វើឱ្យព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់កើតជារូបរាង។ សម្រាប់បងប្អូនវិញ តើព្រះអង្គដែលសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿងនោះ ប្រទានសុភមង្គលបែបណាឱ្យបងប្អូន?។

យើងម្នាក់ៗមានទំនាក់ទំនងពិសេសជាមួយព្រះយេស៊ូ។ ប្រហែលបងប្អូនខ្លះក៏យល់ឃើញថា ព្រះយេស៊ូជាមិត្តសម្លាញ់របស់ខ្លួន។ ខ្លះទៀតថា ព្រះយេស៊ូជារៀមច្បង ឬជាព្រះបរមគ្រូ ជាផ្លូវ ឬជាស្ពាន ដែលនាំខ្លួនទៅកាន់ព្រះបិតា។ ម្នាក់ៗគឺត្រូវតបឆ្លើយនឹងសំណួររបស់ព្រះយេស៊ូដោយនិយាយពីទំនាក់ទំនងយ៉ាងស្និទ្ធស្នាលរបស់ខ្លួនជាមួយនិងព្រះអង្គ ដែលមានព្រះជន្មគង់នៅ។ ព្រះអង្គមិនធ្វើឱ្យយើងរួចផុតពីទុក្ខទេ ប៉ុន្តែព្រះអង្គគង់នៅជាមួយយើងជានិច្ចដរាប ពោលគឺនៅដែលពេលយើងកើតទុក្ខនោះ យើងអាចថ្វាយទុក្ខលំបាករបស់ខ្លួនរួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម។



### ថ្ងៃអាទិត្យទី១៣ ក្នុងរដូវធម្មតា (ថ្ងៃទី១ កក្កដា ឆ្នាំ២០០៧)

"អ្នកកាន់នង្គ័ល ហើយបែរងាកមើលក្រោយ មិនអាចចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ" (លូកា ៩,៥១-៦២)

ព្រះយេស៊ូមានព្រះហឫទ័យដ៏ក្លាហាន យាងទៅក្រុងយេរូសាឡឹម ទាំងដឹងច្បាស់ថា នៅទីនោះ មានគេស្អប់ និងចង់ធ្វើបាបព្រះអង្គ។ រីឯក្រុមសាវ័កវិញ គេមិនយល់ព្រះហឫទ័យ និងគោលបំណងព្រះអង្គទេ គេស្មានថា ព្រះអង្គជាព្រះគ្រីស្ដដែលយាងមកគ្រងរាជ្យដោយប្រើអំណាច និងកម្លាំងបាយបំផ្លាញអ្នកជំទាស់នឹងព្រះអង្គដូចស្ដេចឯទៀតៗ។ ពួកគេយល់ច្រឡំរហូតដល់ចង់កម្ទេចបំផ្លាញអ្នកដែលមិនទទួលព្រះយេស៊ូឱ្យស្នាក់នៅក្នុងភូមិទៀតផង។

ក្រោយមកព្រះយេស៊ូទូន្មានដល់អ្នកដែលចង់ធ្វើជាសាវ័កឬអ្នកចង់ដើរតាមព្រះអង្គ គឺអ្នកនោះត្រូវសុខចិត្តលះបង់អ្វីៗទាំងអស់ ដែលខ្លួនមាន ផ្ញើជីវិតលើព្រះបិតា ដូចព្រះយេស៊ូ ព្រះសមណគោតម ឬដូចជាសន្តហ្វ្រង់ស្វ័រនៅអាស៊ី គឺអស់លោកនេះលះបង់អ្វីៗទាំងអស់ សូម្បីតែផ្ទះសម្បែង ប្រពន្ធកូន ឬក៏ទ្រព្យសម្បត្តិក៏ដោយ។ តើក្នុងចំណោមយើង ជាគ្រីស្ដបរិស័ទ មានប៉ុន្មាននាក់ ហ៊ានប្រព្រឹត្តដូច្នេះ?។ អ្នកមានគ្រួសារត្រូវគិតគូរអំពីប្រពន្ធកូនមែន តែត្រូវសុខចិត្តលះបង់ចោលទ្រព្យសម្បត្តិរបស់ខ្លួនខ្លះសម្រាប់អ្នកក្រជាងខ្លួនផង។ ម្នាក់ៗត្រូវលះបង់នូវប្រយោជន៍ផ្ទាល់ខ្លួនដើម្បីអ្នកដទៃ ពោលគឺត្រូវឱ្យគេសប្បាយជាមុន ទើបយើងសប្បាយជាក្រោយវិញ។



សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!



## រូបភាព

### តើមានរូបអ្វីសម្រាប់លេខនេះ...?



ទិដ្ឋភាពពិធីបុណ្យលើកតម្កើងព្រះនាងម៉ារី និងការដង្ហែរូបសំណាករបស់ព្រះនាង ដែលរៀបចំធ្វើនៅព្រះសហគមន៍បាត់ដំបងកាលពីថ្ងៃទី៣ ឧសភា និងដោយមានការចូលរួមពីគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។



កិច្ចប្រជុំគណៈ-កម្មការកែសម្រួលសៀវភៅចម្រៀង និងអភិបូជាកាលពីថ្ងៃទី១៥ មិថុនា នៅគេហដ្ឋានលោកអភិបាលភូមិភាគភ្នំពេញ។ ក្នុងការកែសម្រួលសៀវភៅទាំងនេះ ក្រុមគណៈកម្មការតែងប្រជុំគ្នាជានិច្ចកាល។



ក្រុមថ្នាក់ដឹកនាំព្រះសហគមន៍កាតូលិក ១០៧ រូបប្រចាំភូមិភាគភ្នំពេញ ជួបប្រជុំគ្នាលើប្រធានបទ: "និទានជីវិតព្រះយេស៊ូក្នុងជីវិតរស់នៅផ្ទាល់ខ្លួនរបស់យើង" នៅសាលាដុនបូស្កូទឹកថ្លា-ភ្នំពេញ នៅថ្ងៃទី១៨ មិថុនា កន្លងទៅ។

Photographed by Sovanna, Socheat



## ដូចម្ដេចហៅថាពាក្យប្រស្នា?

ពាក្យប្រស្នា គឺជារឿងនិទានដែលដកស្រង់ចេញពីជីវិតរបស់នៅប្រចាំថ្ងៃរបស់មនុស្សលោក ហើយក៏ជារឿងនិទានអំពីកិច្ចការដែលគេបានប្រព្រឹត្ត អំពីសំភារៈដែលគេប្រើប្រាស់ជារៀងរាល់ថ្ងៃ (ចង្កៀង មេដំបែ សំណាញ់-ល-) និងអំពីក្ដីស្រមៃ និងការចង់បានរបស់គេមានដូចជា (កំណប់ ត្បូងពេជ្រ គ្រឿងអលង្ការមានតម្លៃ-ល-)។

ពាក្យប្រស្នាគឺជាពាក្យសាមញ្ញធម្មតា និងមានភាពងាយស្រួលក្នុងការនិយាយទៅកាន់មនុស្សទាំងអស់។

ព្រះយេស៊ូបានប្រើពាក្យប្រស្នាសម្រាប់ពន្យល់សេចក្ដីអស្ចារ្យអំពីព្រះជាម្ចាស់។ តើប្រើពាក្យប្រស្នានេះពន្យល់យើងអំពីជីវិតនៅក្នុងប្រទេសរបស់ព្រះយេស៊ូកាលពី២០០០ឆ្នាំមុនយ៉ាងដូចម្ដេច? នៅស្រុកកាលីឡេ ប្រជាជនភាគច្រើនប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ ពួកគេជាអ្នកសាបព្រោះ។ ទោះជាយ៉ាងណា ទឹកដីកាលីឡេមិនសូវជាអំណោយផលល្អប៉ុន្មានទេ កន្លែងខ្លះល្អ ប៉ុន្តែកន្លែងខ្លះដីស្ងួតរឹងថែស គ្មានអ្វីអាចដុះលូតលាស់បានឡើយ និងមានតំបន់ខ្លះជាគុម្ពបន្លា-ល-។ កាលពីជំនាន់ដើម គេធ្វើការសាបព្រោះដោយបាចគ្រាប់ពូជទៅលើដី ហើយគ្រាប់ពូជក៏ធ្លាក់ទៅ តាមកន្លែងផ្សេងៗ ជាច្រើន។ ចំណែកពាក្យប្រស្នានេះវិញ នាំឱ្យយើងមើលឃើញ និងយល់ថា ព្រះយេស៊ូចេះសង្កេតមើល និងចាប់អារម្មណ៍ចំពោះការងារគ្រប់យ៉ាងដែលបងប្អូនបានប្រព្រឹត្ត និងធ្វើជារៀងរាល់ថ្ងៃនៅជុំវិញព្រះអង្គ។

អ្នកនាំសារ

# មិត្តភាពថ្មីរវាងសាលាសន្តហ្វ្រង់ស័រ និងអនុវិទ្យាល័យតេម៉ាស៊ីក

កាលពីថ្ងៃទី២២ ខែឧសភា អ្នកសម្របសម្រួល លោកនាយក លោក-អ្នកគ្រូ បុគ្គលិកសិក្សា និងសិស្សវិទ្យាល័យសន្តហ្វ្រង់ស័រនៃព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹម ចំការទៀង ភូមិភាគភ្នំពេញ បានទទួលស្វាគមន៍យ៉ាងរាក់ទាក់ចំពោះដំណើរទស្សនកិច្ចរបស់លោក-អ្នកគ្រូ៣រូប និងសិស្សានុសិស្ស៣២រូប ដែលមកពីអនុវិទ្យាល័យតេម៉ាស៊ីក Temasek ប្រទេសសិង្ហបុរី ។

ក្នុងដំណើរទស្សនកិច្ចនោះ សិស្សអនុវិទ្យាល័យតេម៉ាស៊ីក បានបង្ហាញអំពីសកម្មភាពនៃសាលាប្រពៃណីទំនៀមទម្លាប់ និងការរស់នៅ នៅក្នុងប្រទេសសិង្ហបុរីតាមរយៈការបញ្ចាំង Slides ។ ជាកិច្ចស្វាគមន៍ លោកប៊ុច វិបុល នាយកវិទ្យាល័យសន្តហ្វ្រង់ស័រ មានប្រសាសន៍ដោយទឹកមុខញញឹមថា សូមទំនាក់ទំនងរវាងវិទ្យាល័យសន្តហ្វ្រង់ស័រ និងអនុវិទ្យាល័យតេម៉ាស៊ីក គឺកាន់តែមានភាពល្អប្រសើរ ដូចជា ចំណងមិត្តភាពរវាងប្រទេសកម្ពុជា និងសិង្ហបុរីដែរ ។

ក្រោយពីកិច្ចស្វាគមន៍ និងទំនាក់ទំនងយ៉ាងស្និទ្ធស្នាល គណៈគ្រប់គ្រងវិទ្យាល័យ សន្តហ្វ្រង់ស័រ បានជ្រើសរើសតំណាងសិស្ស ៣០នាក់ ដើម្បីឱ្យចូលរួមបង្កើននូវទំនាក់ទំនង ឱ្យកាន់តែជិតស្និទ្ធជាមួយនឹងសិស្សានុសិស្ស តេម៉ាស៊ីក តាមរយៈការលេងល្បែងកំសាន្តផ្សេងៗ និងសិក្សាជំនាញកសិកម្មផ្នែកចិញ្ចឹមជ្រូកនិងដំណាំហូបផ្លែ ។ មិនតែប៉ុណ្ណោះ សិស្សានុសិស្សទាំង២ក្រុម ក៏បានធ្វើដំណើរទៅភ្នំវល្លិ ស្ថិតនៅភូមិចំការបីសង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរក្រុងកែបដើម្បីជួយសាងសង់សាលាមត្តេយ្យសម្រាប់កុមារក្រីក្រ និងដាំដំណាំអស់រយៈពេល ៤ថ្ងៃ ។

នៅថ្ងៃ២៥ ខែឆ្នាំដដែល លោកឪពុកអូលីវីយេ អ្នកសម្របសម្រួល លោក-អ្នកគ្រូ និងសិស្សានុសិស្សនៃវិទ្យាល័យសន្តហ្វ្រង់ស័រ ក៏បានរៀបចំពិធីជប់លៀងជូនពរការនិវត្តន៍ទៅមាតុប្រទេសវិញរបស់ប្រតិភូសាលាតេម៉ាស៊ីកផងដែរ ។

ព្រំ សុម៉ាលី

# ពិធីហែព្រះកាយព្រះគ្រីស្ត

កាលពីព្រឹកថ្ងៃទី១០ ខែមិថុនា កន្លងទៅនេះ នៅព្រះសហគមន៍ជុំគីរី ខេត្តកំពត មានរៀបចំនូវពិធីហែព្រះកាយព្រះគ្រីស្ត ដែលដឹកនាំដោយ លោកបូជាចារ្យហ្វ្រង់ស័រ ។



Photo: M. Kunthear

ពិធីមានការចូលរួមពីយុវជន-នារី ប្រមាណ ៣០នាក់ ។ លោកបូជាចារ្យបានធ្វើដំណើរបាចទឹកព្រះពរតាមផ្ទះរបស់គ្រីស្តបរិស័ទចំនួន ៤ផ្ទះ និងបាចគ្រាប់ស្រូវទៅក្នុងស្រែ ដែលបង្ហាញអំពីអត្ថន័យឱ្យផលផ្លែរបស់ប្រជាជនកើនឡើង ។ នេះជាពិធីលើកទី២ ដែលព្រះសហគមន៍បានធ្វើ ។ អ្នកស្រីជូ អាន ប្រធានគណៈកម្មាការនៃព្រះសហគមន៍ជុំគីរី បានឱ្យដឹងថា ពិធីនេះចង់បញ្ជាក់ថា អ្វីដែលយើងធ្វើថ្ងៃនេះ យើងនឹងទទួលបាននូវផលប្រយោជន៍ដែលព្រះជាម្ចាស់ប្រទានឱ្យតាមរយៈព្រះយេស៊ូ ។

មុំ គន្ធា

# ស្នាដៃថ្មីចេញផ្សាយ!




លោកហ្វ្រង់ស័រ ប៉ុងសូដឺ ប្រធានមណ្ឌលវប្បធម៌កាតូលិកកម្ពុជា បានបោះពុម្ពនូវសៀវភៅឈ្មោះថា "កម្ពុជាឆ្នាំសូន្យ" ដែលរៀបរាប់អំពីរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់អ្នកចង់ស្វែងយល់។ តម្លៃក្នុងមួយក្បាល ១៥000រៀល ។ ដូច្នេះ បើសិនប្រិយមិត្តមានចំណាប់អារម្មណ៍ សូមទាក់ទងអាសយដ្ឋាន : ផ្ទះលេខ៥៧ ផ្លូវ១០១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឬទូរស័ព្ទ : ០២៣ ២១១ ២៥៣ ។

# ថាសម្រៀងចេញថ្មី !

មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញផ្សាយនូវស៊ីឌីចម្រៀង វ៉ុលថ្មី វ៉ុលទី៦ ដែលក្នុងនោះ មានការពិពណ៌នាអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង ។ ស៊ីឌីចម្រៀងនេះមាន ១២បទ ។ តម្លៃលក់គឺ ៨ ០០០រៀល ក្នុងមួយស៊ីឌីតែប៉ុណ្ណោះ ។ ដូច្នេះប្រសិនបើប្រិយមិត្តមានចំណាប់អារម្មណ៍ សូមជួយជាវកុំបីខាន។ សូមទំនាក់ទំនងតាមទូរស័ព្ទ: ០១២ ២៤៤ ៧ ៧ ៨ ។

សូមអរគុណ!

## អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !



ភ្នំពេញ : FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។

បាត់ដំបង : FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។

កំពង់ធំ : FM 107.3 Mhz
ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍ ។

កំពង់សោម : FM 100.5 Mhz
ម៉ោង ៧:៣០-៨:០០ ល្ងាចថ្ងៃសៅរ៍ ។

កំពង់ចាម : FM 100.5 Mhz
ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ ។





សូមក្រាបបង្គំទូលថ្វាយព្រះពរជ័យ
ថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ទូលព្រះបង្គំយើងខ្ញុំ ជាអភិបាលបូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា សូមក្រាបបង្គំទូលថ្វាយព្រះពរសព្ទសាធុការ ថ្វាយសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនីនាថ សីហនុ ក្នុងព្រះរាជពិធីចម្រើនព្រះជន្មគម្រប់ ៧១ ព្រះវស្សា យាងចូល ៧២ព្រះវស្សា។ សូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ សូមទ្រង់ព្រះមេត្តាប្រទានព្រះពរជ័យមហាបវរប្រសើរថ្វាយសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រមទាំងព្រះរាជវង្សានុវង្ស សូមបានប្រកបដោយព្រះពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ព្រះសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់កូនចៅចៅទួតរបស់ព្រះអង្គតរៀងទៅ។ សូមសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ មេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីព្រះសហគមន៍កាតូលិកកម្ពុជានៃទូលព្រះបង្គំយើងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ១១ មិថុនា ២០០៧

លោក អេមីល ដេតម្បេ
អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

ជំនឿ




Photo: WORL MISSION

# ឥណ្ឌូនេស៊ី

ប្រទេសហូឡង់ដ៏ បានធ្វើអាណានិគមលើប្រទេសឥណ្ឌូនេស៊ីនាដើមសតវត្សទី១៧ ។ អំឡុងឆ្នាំ១៩៤២ ដល់ឆ្នាំ១៩៤៥ ប្រទេសនេះត្រូវគ្រប់គ្រងដោយប្រទេសជប៉ុន ។ ប្រទេសឥណ្ឌូនេស៊ីបានប្រកាសឯករាជ្យបន្ទាប់ពីជប៉ុនបរាជ័យក្នុងសង្គ្រាមលោកលើកទី២ ។ ក្រោយពីចំណាយពេលអស់៤ឆ្នាំ ដើម្បីចរចា និងមានការសម្របសម្រួលពីអង្គការសហប្រជាជាតិ ប្រទេសហូឡង់យល់ព្រមប្រគល់ឯករាជ្យឱ្យឥណ្ឌូនេស៊ី ។ ប្រទេសឥណ្ឌូនេស៊ីជារដ្ឋមួយ ដែលមានដែនដីកោះធំជាងគេ និងមានប្រជាពលរដ្ឋឥស្លាមរស់នៅច្រើនជាងគេនៅលើពិភពលោកផងដែរ ។ កាលពីខែធ្នូ ឆ្នាំ២០០៤ ប្រទេសឥណ្ឌូនេស៊ីបានរងគ្រោះយ៉ាងដំណំពីរលកយក្សស៊ូណាមី ដែលបណ្តាលឱ្យមនុស្សជាង ១០០០០០នាក់ស្លាប់ និងខាតបង់អស់ទឹកប្រាក់ប្រមាណជា ៤ពាន់លានដុល្លារអាម៉េរិក ។ បន្ទាប់មកទៀត នៅខែមិនា ឆ្នាំ២០០៥ រំជួយដីបានធ្វើឱ្យកោះនីញ៉ាសរបស់ប្រទេសឥណ្ឌូនេស៊ីខូចខាតជាដំណំ ។ នៅឆ្នាំ២០០៥ ប្រទេសឥណ្ឌូនេស៊ីបានឈានដល់កិច្ចព្រមព្រាងសន្តិភាពមួយ ជាមួយពួកបំបែកខ្លួននៅខេត្តអាឆេ ប៉ុន្តែឥណ្ឌូនេស៊ីនៅតែប្រឈមមុខនឹងកម្លាំងទ័ពព្រៃបំបែកខ្លួនមួយចំនួនតូចនៅកោះប៉ាពូ ។

ប្រែសម្រួលដោយថុង យ៉ត

## ទិន្នន័យផ្សេងៗ

ឈ្មោះផ្លូវការ : សាធារណរដ្ឋឥណ្ឌូនេស៊ី ។ ប្រជាពលរដ្ឋ : ២៥ ៥២ ៧៣៩នាក់។ ជនជាតិ : ចាវ៉ា ៤៥% សានដេន ១៤% មេដារ ៧,៥% ម៉ាឡេ ៧,៥% និងដទៃៗទៀត ២៦% ។ ភាសា : បាហាសាឥណ្ឌូនេស៊ី( ផ្លូវការ) អង់គ្លេស ហូឡង់ដ៏ គ្រាមភាសា និងភាសាចាវ៉ា ។ សាសនា : ម៉ូស្លីម ៨៨% ប្រូតេស្តង់ ៥% កាតូលិក ៣% ហិណ្ឌូ ២% និងព្រះពុទ្ធសាសនា ១% និង ដទៃៗទៀត ១% ។ ផ្ទៃដី : ១ ៩១៩ ៤៤០គម² ។ ធនធានធម្មជាតិ : ប្រេងឆៅ ឧស្ម័នធម្មជាតិ សំណប៉ាហាំង នីកែល ព្រៃឈើ បុកស៊ីត ទង់ដែង ដីជីជាតិ សម្រាប់កសិកម្ម ធ្យូងថ្ម មាស និងប្រាក់ ។ រូបិយប័ណ្ណ : រូពី ។ ឯករាជ្យភាព : ថ្ងៃ២៧ ធ្នូ ១៩៤៩ ពីហូឡង់ដ៏ ។

ប្រវត្តិសាស្ត្រសង្គ្រាមរបស់ប្រទេសកម្ពុជានៅតែស្ថិតជាប់ជានិច្ចក្នុងអារម្មណ៍របស់ប្រជាពលរដ្ឋខ្មែរ ។ ទោះបីជារូបភាពដ៏សែនឈឺចាប់ និងសោកសង្រេងនេះបានរលាយបាត់ជាច្រើនឆ្នាំមកហើយក៏ដោយ ។ ប៉ុន្តែបញ្ហាលំបាកៗជាច្រើននៅតែមានបន្សល់ទុកឱ្យអ្នកជំនាន់ក្រោយដោះស្រាយជាបន្តទៀត ។ នេះហើយគឺជាលទ្ធផលនៃសង្គ្រាម ។ ជាការពិតណាស់ បញ្ហាទាំងនេះមិនមែនកើតមានតែចំពោះប្រជាជនខ្មែរនោះទេ អ្វីដែលគួរឱ្យប្រជាជនចាប់អារម្មណ៍នោះគឺមានជនបរទេស ដែលស៊ូទ្រាំអត់ធ្មត់ទទួលរងនូវទុក្ខវេទនាជាមួយប្រជាជនខ្មែរ ទោះបីជាពួកគាត់មានសិទ្ធិត្រលប់ទៅប្រទេសរបស់គាត់វិញយ៉ាងណាក៏ដោយ ។


Photo: M. Kunthear

លោកបូជាចារ្យប៉ុងសូដឺលើកបង្ហាញអំពីសៀវភៅ "កម្ពុជាឆ្នាំសូន្យ"

# លោកប៉ុងសូដឺ: "ដើម្បីឱ្យយុវជនស្គាល់ប្រវត្តិខ្មែរ"




សៀវភៅប្រវត្តិសាស្ត្រ "កម្ពុជាឆ្នាំសូន្យ" មានក្របបង្ហាញអំពីរូបទាហានខ្មែរក្រហមក្មេងៗ ទទួលជ័យជម្នះដើរចូលមកទីក្រុងភ្នំពេញ ក្រោយពីរបបលន់ ណុល បានដួលរលំ

លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដឺ **(François Ponchaud)** អាយុ៦៨ឆ្នាំ ជាជនជាតិបារាំង បានមកប្រទេសកម្ពុជាលើកទី១ នៅឆ្នាំ១៩៦៥ ។ នៅពេលប្រទេសកើតសង្គ្រាម លោកបានរស់នៅភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥ ។ លោកបានឃើញខ្មែរក្រហមបាញ់សម្លាប់ប្រជាជនខ្មែរដោយភ្នែកផ្ទាល់ ។ នៅពេលលោកវិលត្រលប់ទៅកាន់ប្រទេសបារាំងវិញលោកបានសរសេរសៀវភៅមួយស្តីអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាដែលមានភាពល្បីល្បាញនៅប៉ែកអឺរ៉ុបដែលមានចំណងជើងថា: "កម្ពុជាឆ្នាំសូន្យ" ។ នៅឆ្នាំ១៩៩០ លោកក៏ត្រលប់មកប្រទេសកម្ពុជាម្តងទៀត ចំនួន ២សប្តាហ៍ និងនៅឆ្នាំ១៩៩៣ លោកបានមករស់នៅរហូតមកដល់ពេលនេះ ។

ខាងក្រោមនេះ ជាកិច្ចសម្ភាសន៍រវាងអ្នកនាំសារ និងលោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដឺ ទាក់ទងនឹងសៀវភៅ "កម្ពុជាឆ្នាំសូន្យ" ដែលមានអត្ថន័យ និងខ្លឹមសារដូចតទៅ :

**អ្នកនាំសារ :** តើលោកមានគំរោង ឬគំនិតសរសេរសៀវ-ភៅទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរតាំងពីពេលណា ?

**លោកបូជាចារ្យប៉ុងសូដឺ:** ខ្ញុំគ្មានគំរោងសរសេរនូវសៀវភៅនេះទេ ។ ខ្ញុំសរសេរវាដោយចៃដន្យ ដោយសារនៅថ្ងៃទី១៧ ខែមេសា ដ៏មហារុងរឿង ដ៏មហាអស្ចារ្យ នៅពេលដែលខ្មែរក្រហមចូលមកក្នុងទីក្រុងភ្នំពេញ ។ ខ្ញុំឃើញពួកខ្មែរក្រហមជម្លៀសប្រជាជននៅភ្នំពេញទាំងអស់ ទុកតែទីក្រុងនៅទទេស្អាត ។ កាលនោះ ខ្ញុំបានរស់នៅជាមួយនិងខ្មែរក្រហមចំនួន ៣អាទិត្យ ទើបពួកគេបញ្ជូនខ្ញុំទៅកាន់ព្រំដែន ។ នាខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំបានកាន់កាប់ក្រុមមួយខាងផ្នែកព័ត៌មាននៃជនជាតិអាស៊ីទាំងអស់ ។ ខ្ញុំបានធ្វើឯកសារផ្សេងៗ ដូចជា នាខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំធ្វើឯកសារមួយកម្រាស់ប្រហែល ២០ទំព័រ ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំក៏ផ្តើមសរសេរអត្ថបទចុះតាមកាសែតដែរ ។ អត្ថបទដំបូងចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៥ លើកាសែតបារាំង ។ ខ្ញុំនៅប្រមែប្រមូលរកឯកសារផ្សេងៗ ។ ក្រោយមកខ្ញុំឃើញថាកាសែតបារាំងមានសរសេរផ្តេសផ្តាសពីប្រទេសកម្ពុជា ពេលនោះខ្ញុំសរសេរសំបុត្រតវ៉ា និងនៅលើកចុងក្រោយបំផុតនៅដើមខែកុម្ភៈ ឆ្នា១៩៧៦ ។ នាយកកាសែតបារាំងបានឱ្យខ្ញុំសរសេរអត្ថបទមួយ នៅក្នុងកាសែតរបស់គេ ហើយខ្ញុំបានសរសេរអត្ថបទមួយមានចំនួន ៣ទំព័រ ក្នុងរយៈពេល៣ថ្ងៃ ។ ប៉ុន្មានខែក្រោយមក មានអ្នកកាសែតបារាំងបានឃើញនូវឯកសារខ្ញុំ គេក៏ថា ខ្ញុំមានសេចក្តីគ្រប់គ្រាន់ដើម្បីនិពន្ធសៀវភៅមួយ ។ ខ្ញុំថាខ្ញុំមិនមែនជាអ្នកនិពន្ធអ្វីទេ តែពេលនោះគេបានហៅទូរស័ព្ទទៅភ្នាក់ងារម្នាក់ខាងផ្នែកបោះពុម្ពសៀវភៅ ។ យើងក៏បានចុះកិច្ចព្រមព្រៀងនៅខែមេសា ឆ្នាំ១៩៧៦ ។ ដូច្នេះខ្ញុំបានក្លាយទៅជាអ្នកនិពន្ធសៀវភៅដោយចៃដន្យប៉ុណ្ណោះ ។

## អំពីសៀវភៅ

បានបោះពុម្ពប្រហែលជា ១០ ០០០ក្បាល ជាភាសាបារាំង និងភាសាផ្សេងៗ និងមានឈ្មោះល្បី សូម្បីតែនៅប្រទេសកម្ពុជា ក៏មានគេលួចបោះពុម្ពលក់ច្រើនដែរ ។ ប្រហែលជាង ១០ឆ្នាំ ហើយដែលមានគេលួចបកប្រែជាភាសាខ្មែរ តែមានការខុសច្រើន ដែលនាំឱ្យមានការបកប្រែឡើងវិញ ក្នុងកម្រាស់ប្រមាណជាជាង ៣០០ទំព័រ ។

**អ្នកនាំសារ :** តើលោកធ្លាប់យល់ថា នឹងមានអ្វីកើតឡើងទេបន្ទាប់ពីសៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានផ្សព្វផ្សាយទាំងក្នុង និងក្រៅប្រទេស ?

**លោកបូជាចារ្យប៉ុងសូដឺ:** នៅក្នុងសម័យនោះ មិនមានបញ្ហាទេ ។ មានគេនាំយកសៀវភៅនេះទៅជូនលោកអៀង សារី មើល ហើយគាត់បានបដិសេធថា មិនត្រឹមត្រូវឡើយ តាមសៀវភៅនេះ ជាការប្រឌិតឡើងទាំងអស់ ។ ចំណែកឯខាងមតិអន្តរជាតិ សៀវភៅនេះកត្រូវគេទទួលស្គាល់ ហើយត្រូវបានបកប្រែទៅជា ៧ភាសា ដូចជា ភាសាអង់គ្លេស អ៊ីតាលី អេស្ប៉ាញ ជប៉ុន-ល- ។ តាមពិតខ្ញុំខ្លាច នៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់តូចរបស់ខ្ញុំនៅប្រទេសបារាំង ។ ខ្ញុំក៏ខ្លាចថា ខ្មែរក្រហមដាក់គ្រាប់បែក ឬសម្លាប់ខ្ញុំ ។ ប៉ុន្តែខ្មែរក្រហមក្រៅពីប្រទេសរបស់ខ្លួនមិនហ៊ានសម្លាប់មនុស្សទេ ។

**អ្នកនាំសារ :** តើលោកគិតថា សៀវភៅនេះនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះសម្រាប់ប្រជាជនកម្ពុជា និងព្រះសហគមន៍កាតូលិក ?

**លោកបូជាចារ្យប៉ុងសូដឺ:** ដើម្បីឱ្យប្រជាជនកម្ពុជាស្គាល់ ជាពិសេសឱ្យយុវជនស្គាល់ និងដឹងពីព្រឹត្តិការណ៍ ដែលកើតមក ដើម្បីឱ្យយុវជនស្គាល់ពីប្រវត្តិប្រទេសកម្ពុជា និងរិះគិតអំពីប្រវត្តិរបស់ខ្លួន និងអំពីមូលហេតុដែលកើតមានខ្មែរក្រហម ហើយធ្វើយ៉ាងណា ដើម្បីកុំឱ្យកើតមានឡើងម្តងទៀត ។ ខ្ញុំបានដាក់ឯកសារផ្សេងៗនៅជំពូកផ្សេងទៀត គឺពុំមែនដើម្បីបង្ខូចខ្មែរក្រហមទេ ។ ខ្ញុំយល់ឃើញថា ពួកខ្មែរក្រហមសុទ្ធតែជាក្រុមបញ្ញវន្តដែលរៀននៅស្រុកបារាំង ។ ដូច្នេះមុខងាររបស់ខ្ញុំ មិនមែនដាក់ទោសខ្មែរក្រហមទេ មុខងាររបស់ខ្ញុំ គឺឱ្យយល់ហេតុអ្វីបានជា ខ្មែរក្រហមធ្វើដូច្នេះ តែនៅទីបញ្ចប់នៃសៀវភៅខ្ញុំបានស្តីបន្ទោសខ្មែរក្រហមដែរ ។

**អ្នកនាំសារ :** តើលោកគិតថា សៀវភៅនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ព្រះសហគមន៍កាតូលិកដែរទេ ?

**លោកបូជាចារ្យប៉ុងសូដឺ:** តាមពិត ខ្ញុំខ្លាចមែន កាលណាខ្ញុំយកសំណៅរបស់ខ្ញុំទៅបោះពុម្ព តែក្រោយពីខ្ញុំរិះគិតនិងសួរលោកអភិបាលរ៉ាម៉ូស យើងយល់ថាព្រះសហគមន៍កាតូលិកប្រហែលគ្រីស្តបរិស័ទសម័យនោះ បានស្លាប់បាត់ទៅហើយ ។ ប្រសិនបើយើងបោះពុម្ពសៀវភៅប្រហែលជានាំឱ្យគេសម្លាប់មនុស្សខ្លះ ម្យ៉ាងបើព្រះសហគមន៍រងគ្រោះនោះ វាក៏ដូចជាព្រះយេស៊ូដែលរងគ្រោះដោយអយុត្តិធម៌ដែរ ។

**អ្នកនាំសារ :** ក្នុងនាមលោកជាបូជាចារ្យម្នាក់ ហើយមិនមែនជាជនជាតិខ្មែរទៀត តើចំនុចអ្វីដែលលោកផ្តោតគំនិតក៏ដូចជាចាប់អារម្មណ៍ទៅលើប្រវត្តិសាស្ត្រខ្មែរ ?

**លោកបូជាចារ្យប៉ុងសូដឺ:** ខ្ញុំជាគ្រីស្តបរិស័ទ និងមកប្រទេសកម្ពុជានៅឆ្នាំ១៩៦៥ ។ កាលណាយើងមកកាន់ប្រទេសមួយ យើងប្រៀបបានដូចជាសាសនទូត ។ យើងគឺជាតំណាងរបស់សាសនាកាតូលិក ។ ខ្ញុំមកប្រទេសមួយ គឺរួមសាមគ្គីជាមួយប្រជាជនមួយ ។ ដូច្នេះខ្ញុំត្រូវរួមសាមគ្គី ជាមួយនិងប្រជាជនកម្ពុជាដែរ ។ ខ្ញុំបានរួមជាមួយប្រជាជនកម្ពុជាចំនួន៩ឆ្នាំ នៅ ...

... សម័យសម្តេចសីហនុ និង៥ឆ្នាំ នៅសម័យលន់ ណុល ដែលខ្ញុំបានរួមជាមួយប្រជាជនដែលទទួលរងវេទនាដោយសារភ្លើងសង្គ្រាម យើងជួយជនរងគ្រោះដោយសង្គ្រាមនេះ ដែលជាមុខងាររបស់យើង គឺជាគ្រីស្តបរិស័ទ ។ យើងជួយអ្នករងទុក្ខវេទនា ហើយអ្នកខ្លះចោទយើងថា ហេតុអ្វីបានជាមិនរត់នៅសម័យនោះ ពីព្រោះលន់ ណុល ជាបរិវារចក្រពត្តិអាម៉េរិក ។ មែន! លន់ ណុលជាបរិវាររបស់អាមេរិកកាំង តែយើងបំរើប្រជាជនខ្មែរដែលរងគ្រោះ ។ យើងមិនបម្រើលន់ ណុន មិនបម្រើចក្រពត្តិអ្វីនោះឡើយ ។ នៅពេលដែលខ្មែរក្រហមជិតចូលមក សម្តេចសីហនុក៏បានឱ្យយើង ចេញពីប្រទេសកម្ពុជានៅខែកុម្ភះ តែយើងថា ទេ! យើងនៅប្រទេសកម្ពុជាបន្ត ។ នៅខែមីនារដ្ឋាភិបាលបារាំង សូមយើងត្រឡប់ទៅប្រទេសបារាំងវិញ ។ គេក៏យកយន្តហោះមកទទួលអាណិកជនបារាំង តែយើងមិនព្រមចេញ ពីព្រោះយើងថា យើងរួមសាមគ្គីជាមួយប្រជាជនខ្មែរ រហូតដល់ទីបំផុត ។ យើងសុខចិត្តរស់នៅប្រទេសកម្ពុជាដោយយើងស្មានថា ខ្មែរក្រហមសម្លាប់យើង ប៉ុន្តែយើងក៏បានរួមគ្នាជាមួយខ្មែរ នៅពេលសប្បាយ និងនៅពេលវេទនា ក៏យើងនៅតែនៅរួមជាមួយពួកគេ ។ នេះគឺជាមុខងាររបស់ខ្ញុំ ជាគ្រីស្តបរិស័ទ ដែលរួមសាមគ្គីជាមួយ អ្នកដែលវេទនាអ្នកដែលត្រូវគេជិះជាន់ ។ អ្នកដែលគ្មានអ្នកណាការពារ ។ នេះគឺជាបេសកម្ម និងជាមុខងាររបស់ខ្ញុំជាគ្រីស្ត-បរិស័ទ និងជាបូជាចារ្យជារបៀបបំរើព្រះយេស៊ូ ដែលទទួលរងទុក្ខលំបាកដោយគ្មានអ្នកណាការពារ ។

អ្នកនាំសារ : តើហេតុអ្វីបានជាលោកដាក់ឈ្មោះសៀវភៅនេះថា "កម្ពុជាឆ្នាំសូន្យ" ?

លោកបូជាចារ្យប៉ុងស្ងួដ: ឆ្នាំសូន្យ ! ដោយសារខ្ញុំបានមើលសៀវភៅផ្សេងៗដូចជាសៀវភៅអាឡឺម៉ង់ឆ្នាំសូន្យ ។ នៅឆ្នាំ ១៩៤៥ ប្រទេសអាឡឺម៉ង់សូន្យក្រោយសង្គ្រាម ។ ដូច្នេះខ្ញុំថាកម្ពុជាមានសង្គ្រាមជាមួយលោកលន់ ណុលក្រោយសង្គ្រាម គឺសូន្យ ហើយក៏ចាប់ផ្តើមនូវជីវិតថ្មី គឺកម្ពុជាកសាងជីវិតថ្មី ។ ប៉ុន្តែតាមពិតឆ្នាំសូន្យគឺជាឆ្នាំ១៩៧៩ ព្រោះខ្ញុំមិនទាន់ដឹងថាខ្មែរក្រហមបានបំផ្លាញប្រទេសបែបនេះទេ ។ សៀវភៅនេះខ្ញុំបានចាប់ផ្តើមសរសេរ នៅចុងខែកក្កដា ឆ្នាំ១៩៧៦ ហើយចប់រួចរាល់ជាស្ថាពរថ្ងៃ២៤ តុលា ឆ្នាំ១៩៧៦ ។

### បេសកកម្ម

លោកបានសម្ភាសន៍ជនភៀសខ្លួននៅតាមព្រំប្រទល់ខ្មែរ-ថៃ ។ លោកបានធ្វើការប្រឆាំងជាមួយសហគមន៍អន្តរជាតិជាច្រើនចំពោះការដែលពួកគេថា ពួកគេមិនដឹងអ្វីសោះពីសភាពការណ៍ប្រទេសកម្ពុជា តែតាមពិតពួកគេដឹងយ៉ាងច្បាស់ ។ រយៈពេលសរសេរសៀវ-ភៅនេះមានពេលជាង ៣ ខែប៉ុណ្ណោះដោយលោកបានដើរប្រមែប្រមូលឯកសារជាច្រើនកន្លែង ។

## ប្រវត្តិសង្ខេបលោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងស្ងួដ


Photo: DR

លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្ងួដ កើតនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៣៩ នៅប្រទេសបារាំង ហើយលោកត្រូវបានតែងតាំងជាបូជាចារ្យនៅថ្ងៃទី១២ កក្កដា ឆ្នាំ១៩៦៤ ។ លោកគឺជាបូជាចារ្យ មួយរូបក្នុងចំណោមបូជាចារ្យដែលមានវ័យចំណាស់ៗជាច្រើននាក់ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់របបប៉ុលពត និងបានរួមសុខរួមទុក្ខជាមួយប្រជាជនខ្មែរអស់រយៈជាច្រើនឆ្នាំ ។ លោកបូជាចារ្យប៉ុងស្ងួដ បានធ្វើដំណើរមកដល់ប្រទេសកម្ពុជានាថ្ងៃទី៤ វិច្ឆិកា ឆ្នាំ១៩៦៥ ។

លោកមានប្រសាសន៍ថា : "ខ្ញុំបានរស់នៅប្រទេសកម្ពុជាចំសម័យសង្គ្រាម ។ ពេលនោះយៀកកុងបានចាប់ខ្ញុំម្តង និងចង់សម្លាប់ខ្ញុំ តែមានប្រជាជនខ្មែរតវ៉ា បានជាខ្ញុំរួចខ្លួន ។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមបាញ់សម្លាប់ប្រជាជនខ្មែរដោយផ្ទាល់ភ្នែករបស់ខ្ញុំ ។ ខ្ញុំបានរស់នៅខេត្តកំពង់ចាម ។ នៅពេលនោះខ្ញុំបានជួយអាណិកជនវៀតណាមជាច្រើននាក់ឱ្យត្រលប់ទៅស្រុកវិញ ។ នៅសម័យនោះ ខ្ញុំធ្លាប់រត់ដោយថ្មើរជើងកាត់តាមវាលស្រែមកទីក្រុងភ្នំពេញ ។ ខ្ញុំរស់នៅភ្នំពេញរហូតដល់ឆ្នាំ១៩៧៥ ។ លុះដល់ថ្ងៃទី១៧ មេសា ដ៏មហារុងរឿង មហាអស្ចារ្យ ខ្ញុំបានឃើញខ្មែរក្រហមមកដល់ទីក្រុង ។ នៅថ្ងៃទី១៨ ខ្ញុំបាននាំខ្មែរក្រហមធ្វើទស្សនកិច្ចក្នុងទីក្រុងភ្នំពេញ ។ ពេលនោះ ខ្ញុំបានមករស់នៅក្នុងស្ថានទូតបារាំងបាន ៣អាទិត្យ ។ នៅថ្ងៃទី៤ ឧសភា ឆ្នាំ១៩៧៥ ខ្ញុំជាជនបរទេសចុងក្រោយបំផុតដែលវិលត្រឡប់ទៅប្រទេសខ្លួនវិញ ។ ក្រោយមកនៅឆ្នាំ១៩៨០ ខ្ញុំបានត្រលប់មកស្រុកខ្មែរម្តងទៀត តែមកតែពីរសប្តាហ៍ប៉ុណ្ណោះ ។ រហូតមកដល់ឆ្នាំ១៩៩៣ ទើបខ្ញុំបានមករស់នៅប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃ ។ ខ្ញុំមកមុននេះមិនកើត ដោយសារតែខ្ញុំបានសរសេរសៀវភៅ "កម្ពុជាឆ្នាំសូន្យ" ។ ខ្មែរក្រហមស្អប់ខ្ញុំ ។ ម្យ៉ាងខ្ញុំជាអ្នកកាសែត ជួនកាលខ្ញុំនិយាយតាមយោបល់ខ្ញុំដោយខ្ញុំមិនចេះនិយាយលាក់លៀមអ្វីឡើយ ។ ដូច្នេះមុនសម័យអ៊ុនតាក់ មកប្រទេសកម្ពុជា គឺមានការពិបាកដោយសារខ្ញុំមានសត្រូវច្រើនពេក ។

សព្វថ្ងៃនេះលោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្ងួដ គឺជានាយកមជ្ឈមណ្ឌលវប្បធម៌កាតូលិកកម្ពុជា ។ លោកបាននិពន្ធសៀវភៅជាច្រើនក្បាលទាក់ទងនឹងព្រះសហគមន៍ និងរឿងរ៉ាវជាច្រើនទាក់ទងនឹងប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណោះលោកបានកសាងសមិទ្ធផលជាច្រើនជូនដល់ប្រជាជនខ្មែរក្រីក្រនៅតាមទីជនបទដាច់ស្រយាលដូចជាកសាងសាលា និងផ្លូវជាដើម ។

អត្ថបទដោយមុំ គន្ធា





មានស្នូរទះដៃផ្ទួនៗគ្នា រួមជាមួយសំឡេងអ៊ូអរលាយជាមួយនឹងស្នាមញញឹមរបស់កុមារាកុមារី ដែលកំពុងតែអង្គុយត្រៀបត្រាលើកម្រាលប៉ាតង់ពណ៌ខៀវស្ថិតនៅបរិវេណខាងមុខព្រះវិហារដ៏តូចមួយនៅក្នុងភូមិកោះរកាក្រៅ ខេត្តកំពង់ចាម ។

# កុមារនៅតែមានថ្ងៃសិទ្ធិ


ក្រុមកុមារភូមិកោះរកាកំពុងសម្តែងរបាំសន្តិភាព

Photo: R. Bora

កុមារប្រមាណជា ២០០នាក់ កំពុងសប្បាយរីករាយនៅក្នុងឱកាសប្រារព្ធទិវាកុមារអន្តរជាតិ ១ មិថុនា ដែលនេះជាពិធីលើកទី២ ដែលត្រូវបានគេធ្វើឡើងនៅក្នុងភូមិនេះ ។ កម្មវិធីនេះត្រូវបានរៀបចំឡើងដោយក្រុមការងារខាងបណ្ណាល័យរបស់ លោកអ៊ាម ឡៃហ៊ាន និងលោកគ្រូហ៊ាន សុគន្ធ ដែលជាអ្នកណែនាំព្រះសហគមន៍កោះរកាក្រៅ ។

ក្នុងឱកាសដ៏សែនសប្បាយរីករាយនេះ យើងឃើញមានវត្ត-មាននៃលោកគ្រូ អ្នកគ្រូ នាយកសាលា តំណាងភូមិ-ឃុំ និងមានក្រុមយុវជន-នារី ប្រមាណជា ៣០នាក់ ចាំជួយសម្របសម្រួលដើម្បីឱ្យកម្មវិធីមានដំណើរការទៅដោយរលូន ។

លោកម៉េង ហ៊ុ ជានាយកសាលាបឋមសិក្សា កោះរកាក្រៅ បានសម្តែងនូវមតិជាច្រើនដើម្បីលើកទឹកចិត្តទៅដល់កុមារាកុមារី និងបំផុសគំនិតរបស់មាតាបិតាដើម្បីឱ្យមានការគាំទ្រសិទ្ធិកុមារក្នុងឱកាសនោះថា : "យើងត្រូវផ្តល់សិទ្ធិឱ្យកុមារអាចទៅសាលារៀន បានទៀងទាត់ពេលវេលា និងត្រូវចេះបែងចែកកាលវិភាគ រវាងពេលរៀន និងពេលធ្វើការនៅផ្ទះ ហើយត្រូវឱ្យកុមារៗ ចេះបញ្ចេញមតិខ្លួននៅក្នុងគ្រួសារនៅពេលមានការបំពាបំពានពីនរណាម្នាក់" ។ លោកបានបន្ថែមទៀតថា ទិវាកុមារអន្តរជាតិ ដែលមានការឧបត្ថម្ភគាំទ្រអំពីព្រះសហគមន៍កាតូលិកនេះ គឺមិនមែនចង់អូសទាញឱ្យប្អូនៗឱ្យចូលកាន់សាសនាកាតូលិកនោះទេ តែទង្វើនេះគឺធ្វើឡើងដោយសារសេចក្តីស្រលាញ់ និងការអាណិតអាសូរ ។ លើសពីនេះទៀត លោកក៏បានបំផុសឱ្យប្អូនៗកុមារចេះថែរក្សានូវទ្រព្យសម្បត្តិសាធារណៈផ្សេងៗ តួយ៉ាងគឺដូចជាសាលារៀនដែលព្រះសហគមន៍កាតូលិក តែងជួយឧបត្ថម្ភគាំទ្រជារៀងរហូតមកនោះជាដើម ។ ជាមួយគ្នានេះដែរ លោកមេឃុំប៊ូ ធីបានសម្តែងនូវមតិល្អៗទៅកាន់អ្នកចូលរួម ជាពិសេសកុមារាកុមារី ដោយដាស់តឿនឱ្យពួកគេខិតខំរៀនសូត្រទាំងនៅផ្ទះ និងនៅសាលា ។ លោកក៏បាននិយាយអំពីប្រវត្តិនៃទិវាកុមារអន្តរជាតិនេះឱ្យកុមារបានដឹងគ្រប់ៗគ្នាផងដែរ ។

ដោយកំពុងតែមមាញឹកក្នុងការរៀបចំកាដូ អ្នកស្រីរ៉ូសដែលជាតំណាង ឱ្យក្រុមការងាររបស់បណ្ណាល័យ បានសម្តែងមតិដោយចិត្តរំភើបយ៉ាងដូចនេះថា : "ចាប់តាំងតែពីឆ្នាំ២០០០មក យើងចាប់ផ្តើមប្រារព្ធនូវទិវាកុមារអន្តរជាតិដោយសារយើងយល់ថា ក្មេងៗ គឺជាអនាគតប្រទេសជាតិ ក៏ដូចជាព្រះសហគមន៍ដែរ ។ យើងចង់ឱ្យពួកគេ ចេះស្រលាញ់គ្នា និងរួបរួមគ្នាតាំងពីតូចនេះទៅ ។" "ម្យ៉ាងទៀត ខ្ញុំចង់រំឭកនូវរឿងមួយថា នៅទីក្រុងហុងកុង បើគេឃើញកុមារ អាយុក្រោម ១៨ឆ្នាំ កំពុងតែធ្វើការងារនៅតាមកន្លែងផ្សេងៗ ប៉ូលីសនឹងទៅសួររកឪពុកម្តាយរបស់ពួកគេជាក់ជាពុំខាន ។ តែដោយឡែកនៅប្រទេសកម្ពុជា ក៏មានក្មេងៗធ្វើការនៅតាមរោង-ចក្រ និងកន្លែងផ្សេងៗទៀតជាច្រើន ដើម្បីយកកម្រៃដែលពួកគេរកបានមកជួយផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ខ្ញុំក៏មានការពិបាកចិត្តដែរ នៅពេលឃើញដូចនេះ តែខ្ញុំគ្រាន់តែធ្វើតាមសមត្ថភាពរបស់ខ្ញុំតែប៉ុណ្ណោះ ។" នេះគឺជាក្តីព្រួយបារម្ភរបស់អ្នកស្រីរ៉ូស ។ ពិធីជប់លៀងក៏បានប្រព្រឹត្តទៅដោយមានការសម្តែងរបាំប្រពៃណីខ្មែរ និងការសម្តែងកាយវិការយ៉ាងប៉ិនប្រសប់អស្ចារ្យរបស់កុមារាកុមារី និងមានការចែកកាដូដល់ពួកគេដោយបរិយាកាសសប្បាយរីករាយយ៉ាងក្រៃលែង ។

រ៉ូ បូរ៉ា

### សិទ្ធិកុមារ

លោក ប្រធានអង្គការការពារយុត្តិធម៌កុមារ បានមានប្រសាសន៍ប្រាប់ឱ្យដឹងថា : "ទោះបីជាប្រទេសកម្ពុជាមិនទាន់មានច្បាប់ស្តីអំពីសិទ្ធិរបស់កុមារត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏យើងមានរដ្ឋធម្មនុញ្ញ ដែលធានាការពារសិទ្ធិសេរីភាពកុមារដែរ ។ ជាការពិតកុមារទាំងអស់ត្រូវមានសិទ្ធិ និងសេរីភាពស្មើៗគ្នា ប៉ុន្តែនាពេលសព្វថ្ងៃនេះ ការការពារពួកគេនៅមានកម្រិតនៅឡើយ ហេតុដូចនេះហើយ ទើបកុមារមួយចំនួនទទួលរងនូវការរំលោភបំពាន ។ បើតាមគោលការណ៍ច្បាប់កុមារត្រូវមានមេធាវីការពារខ្លួននៅពេលពួកគេជួបរឿងក្តី ។"

ឆៃយ៉ាំជាប្រភេទរបាំមួយដ៏ពេញនិយមរបស់សិល្បៈខ្មែរដែលកើតមានតាំងពីយូរយារណាស់មកហើយ ដែលមាននៅលេងតាមពិធីធំៗ ឬបុណ្យប្រពៃណីជាតិខ្មែរ ។ តើប្រិយមិត្តយល់អ្វីខ្លះអំពីរបាំនេះ ?

# របាំឆៃយ៉ាំ


Photo: L. Sovanna

ក្រុមឆៃយ៉ាំរបស់ព្រះសហគមន៍នៃភូមិភាគបាត់ដំបង

កាលណានិយាយពីឆៃយ៉ាំ យើងនឹងនឹកឃើញភ្លាមដល់ទិដ្ឋភាពនៃរបាំនេះ ។ សព្វថ្ងៃនេះនៅតាមខេត្ត-ក្រុងជាច្រើន គេយករបាំនេះមកលេងក្នុងពិធីបុណ្យដូចជាកឋិន បុណ្យផ្កា ជាដើម ដើម្បីញ៉ាំងឱ្យពិធីកាន់តែឱឡារិកខ្លាំងឡើង ។

ដើមកំណើត

របាំនេះមានឡើងតាំងពីសម័យមនុស្សជំនាន់ដើម នៅក្នុងរជ្ជរ៉ាស៊ីមុនគ្រិស្តសករាជ ហើយតែងមានកំណែប្រែជារឿយៗស្របនឹងការវិវត្តនៃបណ្តាជនរាប់សតវត្សតៗមក រហូតដល់សព្វថ្ងៃ ។ ទោះជាអ៊ីចឹង ឆៃយ៉ាំពុំមានលះបង់របៀបមនុស្សដើមឡើយ ដូចជាការរាំក្រមាច់ក្រមើមញាក់ញ័រជាដើម ។

ប្រដាប់ប្រដារបាំនេះចែកចេញជា២ផ្នែក

គ្រឿងភ្លេង: គ្រឿងភ្លេងសម្រាប់របាំឆៃយ៉ាំមិនមានអ្វីច្រើនឡើយ គឺមានតែក្រាប់ឈើមួយគូឆាបធំមួយ រគាំងមួយ និងស្គរបួន ឬ២-៣ក៏បាន ។

សម្លៀកបំពាក់ : ស្លៀកពាក់តាមនិយមពីដើមមក អ្នករបាំឆៃយ៉ាំត្រូវស្លៀកសំពត់ចងក្បិន ពាក់អាវដៃខ្លីវាលកធំបន្តិចតាមបែបអាវខ្មែរបុរាណ ដែលមានសន្ទះឡេវបី ហើយស៊កចុងអាវ ទៅក្នុងចង្កេះសំពត់ ។ ពណ៌សម្រាប់សម្លៀកបំពាក់នេះមិនកំណត់ទេស្រេចតែនឹងការនិយមចូលចិត្តរបស់ក្រុមនីមួយៗ ។ ក្រៅពីនេះ ក៏មានមុខត្លុកសម្រាប់អ្នកកាន់រគាំង អ្នកកាន់ក្រាប់ ឬក៏អ្នកវាយស្គរណាម្នាក់ដែលពាក់ចេញមក ហើយចាក់ក្បាច់ឡកដាក់គ្នា ។

គ្រឿងរណ្តាប់គ្រូ : ប្រដាប់សម្រាប់ថ្វាយគ្រូគ្មានអ្វីធំដុំទេ គឺមានតែទៀន៥ ធូប៥ ទឹកអប់ពីរកែវ និងស្លាម្លូតែប៉ុណ្ណោះ ។ មុននឹងចាប់លេងគ្រូឆៃយ៉ាំតោងទៅអុជធូប ហើយនិយាយសំបូងសង្រូងអញ្ជើញគ្រូមកសណ្ឋិតនឹងអ្នកលេងទាំងអស់ ។

ការរៀបវង់ : ការរៀបចំវង់លេងរបាំឆៃយ៉ាំមាន ២សណ្ឋាន គឺលេងនៅទីវាលកណ្តាលចំណោមមនុស្ស និងអាចលេងនៅកន្លែងដែលមានរោងល្ខោន អាចចាត់ទុកជាឆាកបាន ។ ចំពោះនៅទីវាល អ្នកលេងឆៃយ៉ាំត្រូវឈររាងជារង្វង់មូល និងទុកចន្លោះកណ្តាលឱ្យធំបន្តិច ឱ្យអ្នកលោតចាក់ក្បាច់ ដែលហៅថា "ឡកឆៃយ៉ាំ" ។ អ្នកលេងឆៃយ៉ាំមានប្រមាណ ១០នាក់ ព្រមទាំងមានស្ត្រីម្នាក់ផងដែរសម្រាប់រាំពន់លោនពីមុខ ។

សម្រង់ពីសៀវភៅសិល្បៈខ្មែរ

## ឆៃយ៉ាំខ្មែរ

ជារបាំប្រពៃណីដែលមានតាំងពីយូរយារណាស់មកហើយ ជាមួយនឹងការវិវត្តនេះ គេមើលឃើញការសម្តែងរបស់វាមានលក្ខណៈខុសប្លែកពីមុនខ្លះៗ ដូចជាបច្ចុប្បន្ននេះមិនត្រឹមតែពាក់មុខត្លុកទេ គឺមានពាក់ជារូបមនុស្សធំៗ ដែលគេហៅថា ទីងមោង ។ ម្យ៉ាងទៀត ឆៃយ៉ាំ ក៏ត្រូវបានគេយកមកសម្តែងនៅពេលមានការប្រកួតកីឡាប្រដាល់ក្បាច់បុរាណខ្មែរផងដែរ ។



# ដំណាំចេកអំបូង

ដំណាំចេកអំបូងត្រូវបានកសិករច្រើនដាំនៅជុំវិញគេហដ្ឋាន ។ ទោះបីវាជាដំណាំងាយស្រួលដាំ ក៏ប៉ុន្តែប្រសិនបើគាត់យកចិត្តទុកដាក់អំពីបច្ចេកទេសបន្តិចនោះ វាក៏អាចបង្កើនទិន្នផលចេកបានដែរ ។


Photo: P. Samphy

ចេកធ្លាក់ត្រយូង ត្រូវឧស្សាហ៍ស្រោចទឹក ទើបផ្លែរីកធំល្អ

បច្ចេកទេសនៃការដាំចេកអំបូង

ការជ្រើសរើសពូជ : កសិករគួរយកកូនចេកដុះចេញ ពីដើមចាស់ដែលមានអាយុចាប់ពី១-២ឆ្នាំ (យកកូនចេកណាដែលឡើងគល់ ឬហៅថាកំពីងចេក) មានកម្ពស់ពី ០,៥-១ម៉ែត្រ និងដុះស្លឹកចាប់ពី២-៣សន្លឹក ។

ការរៀបចំរណ្តៅ និងការដាំ : សូមរៀបចំនូវរណ្តៅទំហំមួយម៉ែត្របួនជ្រុង ជម្រៅ ៨តឹក ដោយទុកគម្លាតពី រណ្តៅមួយទៅរណ្តៅមួយប្រវែង ២ម៉ែត្រ ។ បន្ទាប់មក សូមដាក់សំរាមដូចជា ស្លឹកឈើងាប់ៗ ឬសំរាមពុកផុយចំនួន ១-២បង្គី ទៅក្នុងរណ្តៅ (តែកុំយកស្លឹកឈើស្រស់ៗទៅដាក់ក្នុងរណ្តៅ) ។ ចុងក្រោយ គាត់យកកូនចេកដាក់ដាំនៅក្នុងរណ្តៅ រួចកប់ដីឱ្យលិចគល់កូនចេកដោយយកដីកំប៉ុស្តចំនួន ២បង្គី លុបថែមពីលើបន្ថែមជាការស្រេច ។

ការថែទាំ : កសិករគួរឧស្សាហ៍ស្រោចទឹកជាប្រចាំ នៅពេលចេកជិតធ្លាក់ត្រយូង ។ នៅពេលត្រយូងចេកធ្លាក់ហើយ ត្រូវទុកត្រយូងចេកចេញឱ្យអស់ផ្លែ (មិនត្រូវកាច់ត្រយូងលឿនពេកទេ) ។ កសិករអាចជះទឹកលើផ្លែចេក ២ដង ក្នុងមួយថ្ងៃ (ព្រឹក និងល្ងាច) ដើម្បីជួយជំរុញផ្លែចេកឱ្យឆាប់រីកធំ ។ បើសិនជានៅរដូវប្រាំងវិញ ត្រូវជីករណ្តៅធ្វើជារាងកំពែង នៅជុំវិញគល់ ដែលអាចដក់ទឹកបាននៅពេលស្រោចទឹក ។ ពេលចេកដុះកូនចេញច្រើន គាត់គួររក្សាទុកតែមួយដើមក្នុងមួយគុម្ពបានហើយដើម្បីឱ្យចេកមានផ្លែថ្លោសល្អ ។

ការប្រមូលផល

ចេកដាំរយៈពេល៥-៦ខែ កសិករអាចប្រមូលផលលើកទី១បាន ក្នុង១ស្ទងមានពី១១-១២ស្និត និងមួយស្និតមាន ២០ ទៅ២៥ផ្លែ ។ ប្រមូលផលលើកទី២ ធ្វើឡើងរយៈពេល ៦ខែទៀត ឬធ្វើបន្តគ្នា ។ ជាសន្និដ្ឋានរួម បច្ចេកទេសដាំចេកអំបូងសំខាន់ៗមាន: កាប់រណ្តៅ និងដាក់ជីធម្មជាតិពុកផុយ ។ ដាំគម្លាតគុម្ពឆ្ងាយពីគ្នា២ម៉ែត្រ ។ កប់ចេកដាំឱ្យលិចគល់ ។ នៅរដូវប្រាំង ជីករណ្តៅជុំវិញគុម្ពចេករាងជាកំពែងដើម្បីឱ្យដក់ទឹក ។ ស្រោចទឹកជាប្រចាំពេលចេកធ្លាក់ស្រយូង ។ រក្សាទុកកូនចេកតែ១ដើម ក្នុងមួយគុម្ព ដើម្បីឱ្យចេកមានផ្លែថ្លោសល្អ ។ ជះទឹកលើផ្លែចេក១ថ្ងៃ ២ដង ដើម្បីឱ្យផ្លែឆាប់រីកធំ ។

ទស្សនាវដ្តីកសិករ

## កន្លែងសិក្សា

ប្រសិនបើប្រិយមិត្តមានបំណងចង់សិក្សាអំពីវិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំដំណាំគ្រប់ប្រភេទគឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅសេដាក ឬបុគ្គលិកសេដាកអាចអញ្ជើញទៅបង្រៀនដល់ទីកន្លែងរបស់ប្រិយមិត្តផ្ទាល់តែម្តង ដោយមានការពិភាក្សាលើសេវាកម្មក្នុងតម្លៃសមរម្យ ។ ទូរស័ព្ទ: ០២៣ ៨៨០ ៩១៦ ។



សព្វថ្ងៃនេះបរិស្ថានកំពុងតែបង្កឱ្យមានការព្រួយបារម្ភដល់បញ្ហាសុខភាព និងបង្កឱ្យមានជំងឺផ្សេងៗដូចជាជំងឺដុះសាច់ច្រមុះជាដើម ។ តើការការពារ និងការព្យាបាលជំងឺនេះធ្វើដោយរបៀបណា ?

# ដុះសាច់ច្រមុះ

លោកទេព សោភ័ណ្ឌ ជាវេជ្ជបណ្ឌិតប្រចាំនៅមន្ទីរពេទ្យព្រះកេតុមាលា មានប្រសាសន៍ឱ្យដឹងអំពីបញ្ហា និងការព្យាបាលជំងឺដុះសាច់ច្រមុះថា : "ជំងឺនេះវាកើតឡើងដោយសារបរិស្ថាន ការហុយដី ការបរិភោគអាហារដែលមានជាតិត្រជាក់ដូចជាទឹកកកជាដើម ។ ជាដំបូងវាធ្វើឱ្យគេមានជំងឺផ្តាសាយកាលណាផ្តាសាយញឹកញាប់ពេកធ្វើឱ្យសើមច្រមុះ ដែលធ្វើឱ្យរលាកកោសិកាច្រមុះ ។ ខ្មែរយើងតែងហៅថា "ដុះសាច់ច្រមុះ" ។ លោកបន្តថា នៅពេលកើតជំងឺនេះ វាច្រើនធ្វើឱ្យមានការផ្តាសាយញឹកញាប់ ឈឺក្បាល ក្អក ក្តៅខ្លួន និងរៀនមិនចាំ ។ អ្នកជំងឺគឺតែងមានការលំបាកក្នុងខ្លួននៅពេលមានភ្លៀងដោយគាត់ចាប់ផ្តើមរងាជាងគេ ។

ដើម្បីព្យាបាល អ្នកជំងឺត្រូវតែមករកវេជ្ជបណ្ឌិតជំនាញ ។ បើគាត់ទើបឈឺថ្មីៗ យើងឱ្យថ្នាំគាត់ញ៉ាំ និងតមទឹកកក ឬរបស់ត្រជាក់ហើយគេងឱ្យគ្រប់គ្រាន់ វាអាចធូរបានមួយកម្រិត ។ បញ្ហាសំខាន់របស់ជំងឺនេះគឺ ប្រសិនបើយើងមិនការពារ ឬក៏ព្យាបាលឱ្យទាន់ពេលនោះទេ វាអាចវិវត្តន៍ធ្ងន់ធ្ងរទៅៗ ឬជាជំងឺមហារីកបើរួមផ្សំជាមួយសាច់ដុះថ្មីខុសពីធម្មជាតិ ។ បើតាមការសង្កេត នាបច្ចុប្បន្ននេះ ដងផ្លូវនីមួយៗក្នុងទីក្រុងមានហុយដីខ្លាំង ។ ដូច្នេះនៅពេលធ្វើដំណើរគួរតែពាក់ម៉ាស់ ឬម៉ូក ។ ចំពោះចំណីអាហារ យើងគួរកុំញ៉ាំអាហារណា ដែលមានភាពត្រជាក់ វាបណ្តាលឱ្យកើតផ្តាសាយ ។ ម្យ៉ាងទៀត បើគេងមិនគ្រប់គ្រាន់ វាបណ្តាលឱ្យផ្តាសាយដែរ កាលណាផ្តាសាយ ធ្វើឱ្យរលាកច្រមុះ ។ ជំងឺដុះសាច់ច្រមុះ ច្រើនកើតនៅលើមនុស្សវ័យជំទង់ចាប់ពី១៧-១៨ឆ្នាំ ពីព្រោះវ័យនេះមិនសូវយកចិត្តដាក់ថែខ្លួន ប៉ុន្តែចាប់ពី៤០ឆ្នាំជាង ឡើងទៅមិនសូវជួបទេ ។ ជំងឺនេះព្យាបាលមិនអាចដាច់ទេ បើធ្វើការវះកាត់ ឬដុតបានជាត្រឹម ៧០%-៨០%ប៉ុណ្ណោះ ។

អ្នកនាំសារ


Photo: P. Samphy

លោកវេជ្ជបណ្ឌិតទេព សោភ័ណ្ឌ នៃមន្ទីរពេទ្យព្រះកេតុមាលា

## កន្លែងព្យាបាល

លោកវេជ្ជបណ្ឌិតទេព សោភ័ណ្ឌ មានពិនិត្យ និងព្យាបាលជំងឺទូទៅ នៅផ្ទះលេខ៥៥៨ ផ្លូវជាតិលេខ៥ សង្កាត់ឬស្សីកែវ ខណ្ឌឬស្សី-កែវ ។ ទូរស័ព្ទលេខ : ០១២ ៩៣៤ ៣៧៥ ។

# លោកគង់ ណៃ: "ក្លាយខ្លួនជាអ្នកច្រៀងចាប៉ីដោយងងឹតភ្នែក"


Photo: M. Kunthear

**ចម្រៀងចាប៉ី និងអ្នកច្រៀង ហាក់បីដូចជាឃ្លាតចាកឆ្ងាយពីដួងចិត្តរបស់យុវជន ក៏ដូចជាសិល្បៈខ្មែរ ដោយសារពួកគេទទួលយកឥទ្ធិពលវប្បធម៌បរទេសច្រើន។**

អង្គុយពីមុខផ្ទះលើគ្រែឈើធ្វើពីក្តារ ក្រោមដំបូលតៀមតូចមួយប្រក់ដោយស័ង្កសី ដៃមានកាន់ចាប៉ីយ៉ាងស្រស់ស្អាតជាមួយសម្លៀកបំពាក់អាវយឺតពណ៌លឿងចាស់ខោខ្លៅជើងវែង ដែលអ្នកធម្មតាមើលឃើញថា គាត់គឺជាមនុស្សចាស់ទុំសាមញ្ញ។ ប៉ុន្តែតាមពិតគាត់ជាអ្នកលេង និងច្រៀងចាប៉ីល្បីឈ្មោះម្នាក់ក្នុងចំណោមអ្នកលេងចាប៉ីដងវែងដទៃទៀត នោះគាត់គឺជាលោកតាគង់ ណៃ។ លោកតាគង់ ណៃ ត្រូវបានគេស្គាល់ថា ជាអ្នកច្រៀងចាប៉ីដងវែងដែលមានទេពកោសល្យខ្ពស់មិនចាញ់អ្នកចម្រៀងជើងចាស់ផ្សេងទៀតឡើយ។ បុរសវ័យចំណាស់អាយុ ៦០ឆ្នាំប្លាយរូបនេះ មានប្រសាសន៍ថា: "ខ្ញុំចាប់ផ្តើមរៀនចាប៉ីនេះតាំងពីអាយុ ១៣ ឆ្នាំ។" លោកបន្តថា គាត់បានរៀនតែ២ឆ្នាំប៉ុណ្ណោះក៏ចេញសម្តែងតែម្តង គឺនៅអាយុ ១៥ឆ្នាំ។

ក្នុងកាយវិការអង្គុយបត់ជើងយ៉ាងសុភាព ដូចជាស្រីក្រមុំម្នាក់ លោកតានិយាយរៀបរាប់ពីប្រវត្តិខ្លះៗរបស់គាត់ថា គាត់មានស្រុកកំណើតនៅភូមិដូង ឃុំស្វាយទង ស្រុកកំពង់ត្រាច ក្នុងខេត្តកំពត។ គាត់បានពិការភ្នែកនៅអាយុ៤ឆ្នាំ ដោយសារជំងឺអុចធំដោយកាលនោះ គាត់មិនដឹងថា គាត់ពិការភ្នែកឡើយ។ គាត់ឆ្ងល់ថា: "គ្រប់គ្នា គេដើរបានដោយសេរី តើចុះហេតុអ្វីគាត់ដើរទៅណាមកណាចាំបាច់មានអ្នកកាន់ដៃ?"។ ពេលនោះម្តាយគាត់ប្រាប់ថា: "កូនឯងងងឹតភ្នែក"។ លោកបន្តដោយសំដីទន់ភ្លន់ទៀតថា នៅពេលលោកមានអាយុ ៨ ឆ្នាំ លោកគិតថា លោកពិការភ្នែក ធ្វើអ្វីមិនកើត ក៏សម្រេចចិត្តចាប់យកការរៀនលេងចាប៉ីនេះ តែម្តងគឺរៀនជាមួយឪពុកធំលោកឈ្មោះគង់ ទិត្យ។ តើលោកតារៀនដោយរបៀបណា? លោកតាបានតបតវិញ ដោយវាចាមួយៗថា លោករៀនដោយការទន្ទេញនឹងមាត់ ដោយសួរគ្រូ ឱ្យគ្រូដេញចាប៉ីឱ្យស្តាប់ រួចគាត់ទន្ទេញឱ្យចាំមាត់ បន្ទាប់មកទើបរៀនចាប់ខ្ទង់ដេញដោយខ្លួនឯង។

លើផ្ទៃមុខ ដែលភ្នែកពាក់វ៉ែនតាខ្មៅជាប់ជានិច្ចពុំដែលដោះនោះ អ្នកលេងចាប៉ីរូបនេះក៏បានឱ្យដឹងទៀតថា ឆ្នាំ១៩៩១ លោកបានមកប្រលងច្រៀងចាប៉ីនៅទីក្រុងភ្នំពេញជាប់ចំណាត់ថ្នាក់លេខ១។ នៅឆ្នាំ១៩៩២ លោកត្រូវបានខាងក្រសួងវប្បធម៌អញ្ជើញមកធ្វើការនៅភ្នំពេញ។

សព្វថ្ងៃនេះ ក្រៅពីការលេងចាប៉ីនៅតាមកម្មវិធីផ្សេងៗ តាគង់ ណៃ មានបើកបង្រៀនសិស្សនៅផ្ទះរបស់គាត់ផ្ទាល់តែម្តង។ ក្នុងគ្រួសារ លោកតាមានកូនចំនួន១០នាក់ នៅក្នុងនោះស្រី៤នាក់ និងប្រុស ៦នាក់។ សម្រាប់ថ្ងៃអនាគត លោកតាមិនមានគោលបំណងច្បាស់លាស់ទេ ដោយសារគាត់ពិការភ្នែកធ្វើអ្វីមិនបាន។ ក្រៅអំពីការលេងចាប៉ីមានតែការបង្រៀនកូនចៅជំនាន់ក្រោយឱ្យលេងបន្តនូវកេរមរតកដូនតាកុំឱ្យបាត់បង់ប៉ុណ្ណោះ។

មុំ គន្ធា

## ព្រឹត្តិការណ៍សំខាន់!

- ព្រះសហគមន៍អ្នកលឿងកំពុងចូលរួមជួយកសាងសាលាមត្តេយ្យ ១បន្ទប់ និងសាលាអក្ខរកម្មភាសាខ្មែរដល់បងប្អូនវៀតណាមចំនួន១បន្ទប់ និងមានបណ្ណាល័យសិក្សាមួយបន្ទប់នៅស្ទឹងស្លូត។
- ថ្ងៃទី២៥-៣០ មិថុនា: មានរៀបចំសិក្ខាសាលាការ៉ូល និងសេដ្ឋា ដែលមានយុវជនចូលរួមចំនួន ១៨នាក់ ធ្វើឡើងនៅព្រះសហគមន៍កំពង់ធំ។
- ថ្ងៃទី២៦ មិថុនា: អភិបូជាបញ្ចប់ឆ្នាំសិក្សានៅមណ្ឌលយុវជនកំពង់ចាមក្រុង។
- ថ្ងៃទី២៨ មិថុនា: មានរៀបចំការប្រជុំក្រុមគ្រូអប់រំជំនឿនៅភូមិភាគកំពង់ចាមស្តីអំពីការអប់រំជំនឿ។
- ថ្ងៃទី៣០ មិថុនា: ប្រជុំអំពីការអាន និងចែកចាយព្រះបន្ទូលរវាងអន្តរនិកាយនៃសាសនាគ្រីស្តផ្សេងៗនៅកំពង់ចាមក្រុង។
- ថ្ងៃទី១ កក្កដា: នៅភូមិភាគភ្នំពេញមានរៀបចំសម្ពោធព្រះវិហារថ្មី នៅព្រះសហគមន៍ពោធិ៍ចិនតុង-រាជធានីភ្នំពេញ។
- ថ្ងៃទី១ កក្កដាដូចគ្នា: នៅភូមិភាគបាត់ដំបង ក៏មានការរៀបចំពិធីសម្ពោធព្រះវិហារថ្មីស្រឡាងមួយទៀតដែរ គឺនៅព្រះសហគមន៍កំពង់ឆ្នាំង។


## សេចក្តីជូនដំណឹង!

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានទទួលធ្វើដូចជា បំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD ។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងមានទទួលថតចម្លង CD VCD និង DVD គ្រប់ប្រភេទ។ គ្រប់សេវាកម្មទាំងអស់នឹងគិតគូរក្នុងតម្លៃសមរម្យ។ សូមទំនាក់ទំនងអាស័យដ្ឋាន ឬទូរស័ព្ទ: ០១២ ៣៧៧ ៤៦០។ សូមអរគុណ!



ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ